ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៣០ រថ.បគអថ.ប្រក

# ប្រកាស
# ស្តីពី
# ការកំណត់ទំហំកូតានៃថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា
# សម្រាប់ឆ្នាំ២០២៥

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០០៩៧ រថ.អថ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ស្តីពីការបង្កើតគណៈកម្មការស្ថាប័នដើម្បីរៀបចំគោលការណ៍សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា
- បានឃើញប្រកាសលេខ០១២៦ រថ.បគអថ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការកំណត់ទំហំប្រព័ន្ធ និងទំហំកូតា នៃថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា សម្រាប់ឆ្នាំ២០២៤
- បានឃើញប្រកាសលេខ០៣១២ រថ.បគអថ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការដាក់ឱ្យប្រើប្រាស់បច្ចុប្បន្នភាពគោលការណ៍សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

# សម្រេច

**ប្រការ១ .-**

កំណត់ទំហំកូតានៃប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលសម្រាប់ការអនុវត្តក្នុងឆ្នាំ២០២៥ សម្រាប់អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញលិខិតអនុញ្ញាតឱ្យអ្នកប្រើប្រាស់អគ្គិសនី ដែលស្នើសុំដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលក្នុងឆ្នាំ២០២៥។

**ប្រការ២ .-**

អនុញ្ញាតផ្តល់កូតានៃប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលសម្រាប់ការអនុវត្តឆ្នាំ២០២៥ ដែលមានទំហំសរុបស្មើនឹង៣០ មេហ្គាវ៉ាត់ ជូនអាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ផ្តល់ឱ្យអ្នកប្រើប្រាស់អគ្គិសនីដែលស្នើសុំដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលក្នុងឆ្នាំ២០២៥ ស្របតាមប្រកាសលេខ០៣១២ រថ.បគអថ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យប្រើប្រាស់បច្ចុប្បន្នភាពគោលការណ៍សម្រាប់អនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា។

**ប្រការ៣ .-**

អ្នកប្រើប្រាស់អគ្គិសនីដែលអាចទទួលបានកូតាអនុញ្ញាតឱ្យដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែអ្នកប្រើប្រាស់អគ្គិសនីទាំងនោះ បានបំពេញបែបបទស្នើសុំ និងទទួលបានការអនុញ្ញាតស្របតាមបទប្បញ្ញត្តិ នីតិវិធី និងគោលការណ៍ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានថាមពល អគ្គាធិការ ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា អគ្គនាយកអគ្គិសនីកម្ពុជា ប្រធាននាយកដ្ឋាននានាក្រោមឱវាទក្រសួងរ៉ែ និងថាមពល និងប្រធានមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍១១រោច ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**កែវ-រតនៈ**

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ